# របាយការណ៍វិភាគ

## សេចក្តីព្រាងច្បាប់លទ្ធកម្មសាធារណៈ (២០២២) និងលិខិតបទដ្ឋានពាក់ព័ន្ធកម្ពុជា

# LEGAL ANALYSIS REPORT

## THE DRAFT LAW ON PUBLIC PROCUREMENT (VERSION 2022) AND RELATED REGULATIONS

## របាយការណ៍សង្ខេប

របាយការណ៍នេះត្រូវបានរៀបចំឡើងក្រោមកិច្ចសន្យានៃការផ្តល់សេវាកម្មដល់វិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយ និងអង្គការតម្លាភាពកម្ពុជា សម្រាប់ការស្រាវជ្រាវនិងវិភាគក្របខណ្ឌច្បាប់និងបទប្បញ្ញត្តិគ្រប់គ្រងលទ្ធកម្មសាធារណៈ និងការអនុវត្ត នៅកម្ពុជា។ ជាលទ្ធផលនៃការធ្វើលទ្ធកម្មគម្រោង ការិយាល័យមេធាវី សិង្ហាល័យ បានធ្វើការសិក្សាស្រាវជ្រាវនិងវិភាគលើឯកសារនិងព័ត៌មានដែលមានស្រាប់ អំពីក្របខណ្ឌច្បាប់និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈនៅព្រះរាជាណាចក្រកម្ពុជា។ ដោយសារតែក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់លទ្ធកម្មសាធារណៈ ដែលកំពុងស្ថិតនៅដំណាក់កាលពិភាក្សាជាសាធារណៈ របាយការណ៍នេះនឹងយកសេចក្តីព្រាងច្បាប់លទ្ធកម្មសាធារណៈជាឯកសារគោល ក្នុងការសិក្សានិងវិភាគ។ ដើម្បីផ្តល់មតិយោបល់ ការសិក្សានិងវិភាគត្រូវបានធ្វើឡើងតាមការវិភាគបែបប្រៀបធៀបច្បាប់ស្តីពីលទ្ធកម្មសាធារណៈ (ទាំងច្បាប់នាពេលបច្ចុប្បន្ន និងសេចក្តីព្រាងច្បាប់) ជាមួយនឹងក្របខណ្ឌច្បាប់លទ្ធកម្មសាធារណៈ ដែលប្រទេសកម្ពុជាកំពុងអនុវត្តនាពេលបច្ចុប្បន្ន និងឧត្តមានុវត្តអន្តរជាតិ រួមមាន ច្បាប់លទ្ធកម្មសាធារណៈគម្រូរបស់ UNICITRAL និងច្បាប់លទ្ធកម្មសាធារណៈរបស់ប្រទេសដ៏ទៃ។

របាយការណ៍នេះផ្តោតសំខាន់ទៅលើបញ្ហាបច្ចេកទេសចំនួនប្រាំពីររួមមាន ១) តម្លាភាព ២) ការគ្រប់គ្រង ៣) គណនេយ្យភាព និងសុចរិតភាព ៤) ការគ្រប់គ្រងនិងត្រួតពិនិត្យ ៥) សិទ្ធិប្តឹងទាមទារ ៦) ការចូលរួមពីសាធារណជន និង ៧) ការបើកចំហរ និងបរិយាបន្ន។ របាយការណ៍នេះបានផ្តល់ជាយោបល់មួយចំនួនដូចខាងក្រោម៖

### ១. តម្លាភាព

ដើម្បីបំពេញចំណុចខ្វះខាតក្នុងច្បាប់ដែលមិនបានទាមទារឱ្យមានការផ្សព្វផ្សាយជាសាធារណៈអំពីនីតិវិធីចរចា និងលទ្ធកម្មសាធារណៈពីប្រភពតែមួយ របាយការណ៍ស្នើឱ្យសេចក្តីព្រាងច្បាប់លទ្ធកម្មសាធារណៈតម្រូវឱ្យមានការផ្សព្វផ្សាយជាសាធារណៈអំពីវិធីទាំងនេះ។ ជាងនេះទៅទៀត ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគួរត្រូវបានយកមកប្រើប្រាស់ ដើម្បីបង្កើនតម្លាភាពនៃការធ្វើលទ្ធកម្មសាធារណៈ។ ដូចនេះ សេចក្តីព្រាងច្បាប់លទ្ធកម្មសាធារណៈគួរមានបញ្ញត្តិបង្កើតនិងទទួលស្គាល់ឱ្យមានថ្នាលព័ត៌មានលើបណ្តាញអ៊ីនធើណេត ដើម្បីបង្ហាញព័ត៌មានសាធារណៈពាក់ព័ន្ធនឹងនីតិវិធីលទ្ធកម្មទាំងមូល រួមមាន ការអញ្ជើញឱ្យចូលរួមដេញថ្លៃ អត្តសញ្ញាណរបស់អ្នកដេញថ្លៃ អ្នកដេញថ្លៃដែលត្រូវបានជ្រើសរើស និងព័ត៌មានសំខាន់ៗអំពីកិច្ចសន្យាដែលត្រូវបានចុះហត្ថលេខាឬផ្តល់ជូនអ្នកដេញថ្លៃដែលទទួលបានគម្រោង។

### ២. ការគ្រប់គ្រង

របាយការណ៍បានស្នើឱ្យសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈគួរបញ្ចូលនូវវិធាននិងនីតិវិធីគោលៗឬចម្បងពាក់ព័ន្ធនឹងការរៀបចំថវិកាសម្រាប់ចំណាយទៅលើគម្រោងដែលទទួលបានពីលទ្ធកម្មសាធារណៈ ដែលមានតម្រូវការចំណាយរយៈពេលមធ្យម។ ដូចនេះ សេចក្តីព្រាងច្បាប់និងបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ គួរ ១) ពង្រឹងក្របខណ្ឌចំណាយរយៈពេលមធ្យម សម្រាប់រៀបចំផែនការចំណាយលទ្ធកម្មសាធារណៈ ២) ទាមទារឱ្យមានសង្ខេប

អំពីគម្រោងលទ្ធកម្មសាធារណៈនិងការចំណាយភ្ជាប់ជាមួយឯកសារថវិកាប្រចាំឆ្នាំ សម្រាប់ដាក់ជូនសភាពិនិត្យ និងផ្សព្វផ្សាយជាសាធារណៈ និង ៣) មានរបាយការណ៍អនុវត្តគម្រោងលទ្ធកម្មសាធារណៈ ភ្ជាប់ជាមួយនឹងរបាយការណ៍អនុវត្តថវិកា ដើម្បីដាក់ជូនសភាពិនិត្យនិងផ្សព្វផ្សាយជាសាធារណៈ។ ជាងនេះទៅទៀត របាយការណ៍នេះក៏បានស្នើឱ្យរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាពិនិត្យលទ្ធភាពបង្កើតឱ្យមានការការពារផ្លូវច្បាប់ដល់គណៈកម្មការឬគណៈកម្មាធិការលទ្ធកម្មនិងអ្នករាយការណ៍អំពីបញ្ហាអនុលោមភាពក្នុងលទ្ធកម្មសាធារណៈ។

### ៣. គណនេយ្យភាព និងសុចរិតភាព

របាយការណ៍នេះបានស្នើឱ្យសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈចាត់ទុកវិធីសាស្រ្តដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ ជាវិធីសាស្រ្តលទ្ធកម្មទូទៅនិងស្វ័យប្រវត្តិ ជាជាងការកំណត់ថា វិធីសាស្រ្តដេញថ្លៃដោយប្រកួតប្រជែងនេះគឺជាវិធីសាស្រ្តលទ្ធកម្មដែលមានកម្រិតតម្លាភាពខ្ពស់ និងដែលត្រូវជម្រុញឱ្យប្រើក្នុងលទ្ធកម្មសាធារណៈ។ ដូចនេះ ប្រសិនបើវិធីសាស្រ្តដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ ត្រូវបានកំណត់ជាវិធីសាស្រ្តលទ្ធកម្មទូទៅនិងស្វ័យប្រវត្តិ នោះវិធីសាស្រ្តដេញថ្លៃផ្សេងៗទៀត នឹងត្រូវយកមកពិចារណានិងប្រើប្រាស់នៅកាលៈទេសៈពិសេសតែប៉ុណ្ណោះ។

ដោយសារតែគណនេយ្យភាពនិងសុចរិតភាពទាមទារឱ្យមានវិធាននៃការបង្កាប់បញ្ហាច្បាស់លាស់ ដូចនេះ របាយការណ៍នេះបានស្នើឱ្យសេចក្តីព្រាងច្បាប់លទ្ធកម្មសាធារណៈចែងអំពីកាតព្វកិច្ចក្នុងការរក្សាកំណត់ត្រានៃការសម្រេចចិត្តក្នុងលទ្ធកម្ម ដើម្បីផ្តល់ជាកំណត់ហេតុជាលាយលក្ខណ៍ អក្សរបញ្ជាក់អំពីនីតិវិធីនៃការសម្រេចចិត្ត នៅក្នុងដំណាក់កាលនៃស្ថាប័នអនុវត្តលទ្ធកម្ម និងស្ថាប័នគ្រប់គ្រងលទ្ធកម្មសាធារណៈ គឺក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ម្យ៉ាងវិញទៀត ក្របខណ្ឌច្បាប់នាពេលបច្ចុប្បន្ននៅមិនទាន់កំណត់អំពីលទ្ធភាពតាមផ្លូវច្បាប់ក្នុងការលុបចោលការអនុវត្តលទ្ធកម្មសាធារណៈ។ ដូចនេះ សេចក្តីព្រាងច្បាប់លទ្ធកម្មសាធារណៈគួរចែងបញ្ញត្តិគ្រប់គ្រងលទ្ធភាព នៃការលុបចោលការអនុវត្តលទ្ធកម្មសាធារណៈ រួមមានកាតព្វកិច្ចក្នុងការកត់ត្រាហេតុផលដែលបណ្តាលឱ្យមានការលុបចោល ការអនុវត្តលទ្ធកម្មសាធារណៈនោះ។

ចំពោះមុខងារ របាយការណ៍នេះបានស្នើការពិចារណាទៅលើការផ្ទេរមុខងារត្រួតពិនិត្យលទ្ធកម្មទៅស្ថាប័នដោយឡែកក្រៅពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានមុខងារគ្រប់គ្រងលទ្ធកម្មសាធារណៈរួចទៅហើយ ដើម្បីធានាឱ្យបាននូវតុល្យភាពនៃអំណាចនិងជៀសវាងបញ្ហាទំនាស់ផលប្រយោជន៍។

ជាមួយគ្នានេះ របាយការណ៍នេះក៏បានស្នើឱ្យសេចក្តីព្រាងច្បាប់លទ្ធកម្មសាធារណៈចែងនូវបញ្ញត្តិសារធាតុ ជាបញ្ញត្តិពិសេសលុបលើបញ្ញត្តិទូទៅនៃច្បាប់កិច្ចសន្យា ដើម្បីមោឃៈរាល់កិច្ចសន្យាលទ្ធកម្ម ដែលត្រូវបានធ្វើឡើងដោយមិនស្របច្បាប់។ ប្រការនេះអាចជួយកាត់បន្ថយបញ្ហាពុករលួយដែលផ្តើមឡើងដោយវិស័យឯកជន ដើម្បីទទួលបានកិច្ចសន្យាលទ្ធកម្មសាធារណៈ។

**៤. ការគ្រប់គ្រងនិងត្រួតពិនិត្យ**

របាយការណ៍នេះបានស្នើឱ្យមានការបង្កើតបទប្បញ្ញត្តិជាក់លាក់ដើម្បីកំណត់អំពីនីតិវិធីអនុវត្ត រួមមានប្រកាសស្តីពីវិធាននិងនីតិវិធីនៃការទទួលយកទំនិញនិងសេវា។ រាល់គម្រោងលទ្ធកម្មសាធារណៈដែលត្រូវបានបញ្ចប់ហើយ គួរត្រូវបានពិនិត្យនិងទទួលយកដោយស្ថាប័នមានសមត្ថកិច្ច តាមច្បាប់ បទប្បញ្ញត្តិ និងកិច្ចសន្យាជាធរមាន។ រាល់ទ្រព្យដែលជាលទ្ធផលនៃការធ្វើលទ្ធកម្មសាធារណៈនោះត្រូវបានចាត់ទុកជាទ្រព្យរដ្ឋ ដែលត្រូវកត់ត្រាទុកក្នុងតារាងតុល្យការរបស់រដ្ឋ និងគ្រប់គ្រងដោយស្ថាប័នដែលមានសមត្ថកិច្ចគ្រប់គ្រងទ្រព្យរដ្ឋ។

ដើម្បីចូលរួមយ៉ាងសកម្មក្នុងការគ្រប់គ្រងហានិភ័យ របាយការណ៍នេះបានផ្តល់ជាយោបល់ឱ្យសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈផ្តល់មុខងារជូនស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងហានិភ័យ ក្នុងលទ្ធកម្មសាធារណៈ និងដាក់កាតព្វកិច្ចឱ្យស្ថាប័នអនុវត្តលទ្ធកម្មវិភាគអំពីហានិភ័យនៃភាពមិនអនុលោមនិងអំពើពុករលួយ នៅក្នុងការអនុវត្តលទ្ធកម្មសាធារណៈជាទូទៅ។ ការតាមដាននិងត្រួតពិនិត្យគណនេយ្យភាពនិងសុចរិតភាពនៃការអនុវត្តលទ្ធកម្ម តម្រូវឱ្យមានការផ្តល់ជាការការពារផ្នែកច្បាប់ដល់អ្នករាយការណ៍អំពីបញ្ហាអនុលោមភាពក្នុងលទ្ធកម្មសាធារណៈផងដែរ។ ដូចនេះ របាយការណ៍នេះបានស្នើឱ្យបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មនូវវិធីសាស្ត្រដែលអនុញ្ញាតឱ្យភាគីពាក់ព័ន្ធអាចរាយការណ៍អំពីរាល់ភាពមិនអនុលោមនៅក្នុងគម្រោងលទ្ធកម្មសាធារណៈ និងផ្តល់ការការពារនៅពេលមានហេតុការនៃការរាយការណ៍កើតឡើង។

**៥. សិទ្ធិប្តឹងទាមទារ**

គោលការណ៍ទូទៅនៃច្បាប់ គឺការកំណត់ឬបែងចែកមុខងារក្នុងការសម្រេចនិងដោះស្រាយបញ្ហាមួយ។ ភ្ជាប់ជាមួយនឹងការបង្កើតឬបែងចែកមុខងារត្រួតពិនិត្យទៅស្ថាប័នឯករាជ្យក្រៅពីស្ថាប័នដែលគ្រប់គ្រងលទ្ធកម្មសាធារណៈ របាយការណ៍នេះក៏បានផ្តល់អនុសាសន៍បន្ថែមឱ្យប្រគល់មុខងារនៃការដោះស្រាយវិវាទជូនស្ថាប័នមួយដោយឡែកផ្សេងទៀត ក្រៅពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីជៀសវាងបញ្ហាទំនាស់ផលប្រយោជន៍។ ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងអនុលោមភាពក្នុងការអនុវត្តលទ្ធកម្មសាធារណៈ របាយការណ៍នេះបានស្នើឱ្យមានការបង្កើតនូវនីតិវិធីដើម្បីដោះស្រាយបញ្ហាឬផ្តល់បដិទានតាមផ្លូវច្បាប់ជូនដល់ភាគីដែលមានប្រយោជន៍រួមមានសាធារណជនជាដើម ដែលបុគ្គលទាំងនោះគួរមានសិទ្ធិទាមទារឬតវ៉ា លើបញ្ហាមួយចំនួនពាក់ព័ន្ធនឹងការអនុវត្តលទ្ធកម្ម រួមទាំងវិធីសាស្ត្រនៃការធ្វើលទ្ធកម្មជាដើម។ ដើម្បីភាពប្រាកដប្រជានៃច្បាប់ របាយការណ៍នេះបានស្នើឱ្យមានការកំណត់អាជ្ញាយុកាលសម្រាប់អ្នកដេញថ្លៃអាចដាក់បណ្តឹងទាមទារ ដើម្បីទទួលបានការដោះស្រាយដោយស្ថាប័នមានសមត្ថកិច្ច មុនត្រូវបានតវ៉ាបន្តទៅតុលាការ ដោយបូករួមទាំងនីតិវិធីតវ៉ានៅពេលដែលនីតិវិធីត្រូវបានផ្អាកជាដើម។

ម្យ៉ាងវិញទៀត សេចក្តីព្រាងច្បាប់លទ្ធកម្មសាធារណៈ ក៏គួរតែពិចារណាកំណត់មជ្ឈត្តកម្មជាជម្រើសនៃការដោះស្រាយជម្លោះក្នុងលទ្ធកម្មសាធារណៈផងដែរ។

## ៦. ការចូលរួមពីសាធារណជន

របាយការណ៍នេះបានផ្តល់ជាមតិយោបល់ឱ្យមានការបង្កើតប្រព័ន្ធមួយដែលអនុញ្ញាតឱ្យប្រជាជននិងភាគីពាក់ព័ន្ធអាចផ្តល់យោបល់ទៅលើផែនការលទ្ធកម្ម និងគម្រោងលទ្ធកម្ម ដោយយកគណនេយ្យភាពសង្គមដែលបង្កើតឡើងដោយរដ្ឋបាលថ្នាក់ក្រោមជាតិជាគម្រូ។ ដើម្បីជម្រុញឱ្យមានការចូលរួមពីសាធារណជនឱ្យមានប្រសិទ្ធភាព ព័ត៌មានអំពីគម្រោងលទ្ធកម្មសាធារណៈរួមមានព័ត៌មានអំពីតម្លៃ គុណភាព និងការអនុវត្ត គួរត្រូវបានបោះផ្សាយជូនសាធារណជន ជាទម្រង់សង្ខេបនិងងាយយល់។ ជាងនេះទៅទៀត សាធារណជនអាចត្រូវបានតំណាងដោយសមាជិកសភាឬក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដើម្បីពិនិត្យនិងសម្រេចលើការចំណាយទៅលើគម្រោងលទ្ធកម្មសាធារណៈ។ ដូចនេះ រាល់ថវិកាដែលត្រូវចំណាយទៅលើគម្រោងលទ្ធកម្មសាធារណៈនិងផែនការគម្រោងលទ្ធកម្មសាធារណៈ គួរត្រូវបានរាយការណ៍ជាសង្ខេបជូនសភានិងក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ភ្ជាប់ជាមួយនឹងឯកសារថវិកាប្រចាំឆ្នាំ សម្រាប់ឱ្យសភានិងក្រុមប្រឹក្សាថ្នាក់ក្រោមជាតិពិនិត្យនិងសម្រេច។ នារាល់ចុងឆ្នាំហិរញ្ញវត្ថុ របាយការណ៍សង្ខេបនៃការអនុវត្តគម្រោងលទ្ធកម្មសាធារណៈត្រូវរៀបចំឡើងនិងដាក់ជូនសភានិងរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីពិនិត្យនិងសួរនាំ ប្រសិនបើមានជាចម្ងល់។

## ៧. ការបើកចំហរនិងបរិយាបន្ន

របាយការណ៍នេះបានស្នើឱ្យសេចក្តីព្រាងច្បាប់ដោះស្រាយបញ្ហានៅចំពោះមុខបីធំៗគឺ ១) ការលុបចោលនូវរនាំងការិយាធិបតេយ្យនៃការចុះបញ្ជីនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីអាចចូលរួមដេញថ្លៃ ២) ការពិចារណាទៅលើការជម្រុញឱ្យមានការចូលរួមពីសហគ្រាសធុនតូចនិងមធ្យម និង ៣) ការបង្កើតឱ្យមានបទដ្ឋាននៃនីតិវិធី ដែលអាចឆ្លើយតបទៅនឹងគោលនយោបាយសេដ្ឋកិច្ចនិងសង្គម សម្រាប់ប្រើប្រាស់វិធីសាស្ត្រ“កិច្ចសន្យាជាមួយនឹងសហគមន៍”ឱ្យមានប្រសិទ្ធភាព ដូចដែលបានកំណត់ក្នុងច្បាប់និងសេចក្តីព្រាងច្បាប់លទ្ធកម្មសាធារណៈ។